**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ : ០៥៤ សព្រក

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី ផលប៉ះពាល់លើតំបន់ស៊ីវិល និងការគាំពារពលរដ្ឋភៀសសឹក ដោយសារសង្គ្រាមឈ្លានពានទាតទីទឹកដីរបស់រដ្ឋាភិបាលក្រុងបាងកក និងយោធាថៃ ចាប់ពីម៉ោង៧ព្រឹក រហូតដល់ម៉ោង១រសៀល ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៥

គិតចាប់ពីថ្ងៃទី៧ ខែធ្នូ រហូតដល់ម៉ោង១រសៀល ថ្ងៃទី១៨ ខែធ្នូនេះ អំពើឈ្លានពានរបស់រដ្ឋាភិបាលក្រុងបាងកក និងយោធាថៃលើកម្ពុជា មិនរើសគោលដៅ ជាពិសេសការផ្លោង និងទម្លាក់គ្រាប់លើតំបន់ស៊ីវិល បានបណ្តាលឱ្យពលរដ្ឋកម្ពុជាស្លាប់ចំនួន១៨នាក់ របួសចំនួន៧៩នាក់ ជនភៀសសឹកជាង១៤ម៉ឺនគ្រួសារ ស្មើនឹងជិត៤៨ម៉ឺននាក់ ក្នុងនោះស្ត្រីជាង២៤ម៉ឺននាក់ និងកុមារជាង១៣ម៉ឺននាក់។ មានខេត្តមិនជាប់ព្រំដែនថៃចំនួន៥ហើយ បានទទួលជនភៀសសឹក។

**បើគិតពីម៉ោង៧ព្រឹក រហូតដល់ម៉ោង១រសៀល ថ្ងៃទី១៨ ខែធ្នូ ផលប៉ះពាល់មានដូចខាងក្រោម៖**

**១-ករណីពលរដ្ឋស្លាប់ និងរបួស៖** ពុំមានពលរដ្ឋស្លាប់ និងរបួសថ្មីទេ។

**២-ករណីពលរដ្ឋនៅជំរំសុវត្ថិភាព៖ ខេត្តព្រះវិហារ**មានជនភៀសសឹក ១០.៨២៦គ្រួសារ ស្មើនឹង ៣៤.៥២១នាក់ **ឧត្តរមានជ័យ** ១១.៤២៦គ្រួសារ ស្មើនឹង ៣៨.១៩១នាក់ **បន្ទាយមានជ័យ** ៥៤.៥០២គ្រួសារ ស្មើនឹង ១៨២.៨២០នាក់ **បាត់ដំបង** ១២.៩៣៣គ្រួសារ ស្មើនឹង ៤៦.៤៤១នាក់ **ពោធិ៍សាត់** ៩០០គ្រួសារ ស្មើនឹង ៣.២២១នាក់ **កោះកុង** ២.៣២៨ គ្រួសារ ស្មើនឹង ៨.៤១៣នាក់ **សៀមរាប** ៤១.៤៨១គ្រួសារ ស្មើនឹង ១៣១.៥៥១នាក់ **ខេត្តកំពត** ៣.១២០គ្រួសារ ស្មើនឹង ៩.៧៣៧នាក់ **កំពង់ស្ពឺ** ៨២៦គ្រួសារ ស្មើនឹង ២.៩៦៧នាក់ **កណ្តាល** ១.៧៩១គ្រួសារ ស្មើនឹង ៦.០៥៧នាក់ និង**កំពង់ចាម** ៤.៥៦២គ្រួសារ ស្មើនឹង ១៤.១៣៧នាក់។ សរុបពីដើមគ្រាមក ជនភៀសសឹកបានកើនដល់ **១៤៤.៦៩៥គ្រួសារ ស្មើនឹង ៤៧៨.០៥៦នាក់** ក្នុងនោះស្ត្រីជាង២៤ម៉ឺននាក់ និងកុមារជាង១៣ម៉ឺននាក់។

**៣-ករណីបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធរបស់ស៊ីវិល៖** ខូចខាតអគារ១ ដំបូលឃ្លាំង១ និងរថយន្តមួយចំនួន ដោយសារកងទ័ពថៃប្រើយន្តហោះ F-16 ទម្លាក់គ្រាប់ចំនួន៣គ្រាប់ ចូលភូមិសាស្ត្រភូមិផ្សារកណ្តាល សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត។ ជាបឋម គិតពីថ្ងៃទី៧ ខែធ្នូមក ការខូចខាតសរុបមាន ផ្ទះប្រជាពលរដ្ឋ៦៧ខ្នង សាលារៀន១ទីតាំង មណ្ឌលសុខភាព១ទីតាំង ប្រាសាទបុរាណ១ វត្តអារាម៤ទីតាំង សាលាធទាន១ទីតាំង កុដិព្រះសង្ឃ១ទីតាំង អគារការិយាល័យគយ និងរដ្ឋាករចំនួន១អគារ អគារកាស៊ីណូ៤ទីតាំង សណ្ឋាគារ៣ទីតាំង អគារ៤ខ្នង មណ្ឌលកសិកម្មសហគមន៍១ទីតាំង ស្ពានថ្ម១ ស្ពានដែក១ ក្បាលស្ពាន១កន្លែង ស្ថានីយ៍ប្រេង១ទីតាំង មធ្យោបាយដឹកជញ្ជូន៥គ្រឿង ដំបូលឃ្លាំង១ ឃ្លាំងទិញដំឡូង១ទីតាំង និងស្ពានបុរាណ១កន្លែង។ ក្រៅពីនេះ សេវាជាមូលដ្ឋាន ដូចជា រដ្ឋបាល សុខាភិបាល និងអប់រំតាមក្រុង ស្រុក ឃុំ-សង្កាត់ ក៏បានផ្អាកស្ទើរទាំងស្រុង ដោយសារតែភាគីថៃបង្កើនការវាយប្រហារមកលើតំបន់ស៊ីវិល ទាំងតាមជើងគោក ជើងទឹក និងជើងអាកាស។

**ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** មានមោទនភាព និងកត់ត្រាទុកនូវកម្លាំងមហាសាមគ្គីជាតិ កំពុងមានចលនាកាន់តែសកម្មរឹងមាំខ្ពស់ត្រដែត ដោយកូនខ្មែរគ្រប់រូប នៅគ្រប់ទីកន្លែងទូទាំងពិភពលោក បានរៀញស្មារតីជាតិជាធ្លុងមួយ ប្រកៀកស្មាគាំទ្រ និងជឿជាក់យ៉ាងមុតមាំលើយុទ្ធសាស្ត្រការពារជាតិរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និង **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**។ មហាកម្លាំងសាមគ្គីនេះ បានផ្តល់ថាមពលដ៏មហិមាជូនដល់កម្លាំងកងយោធពលខេមរភូមិន្ទ និងនគរបាលការពារព្រំដែន នៃក្រសួងមហាផ្ទៃ ដែលកំពុងកៀកស្មាប្រយុទ្ធការពារបូរណភាពទឹកដី និងអធិបតេយ្យភាពជាតិ ប្រកបដោយម្ចាស់ការ អង់អាចក្លាហាន ឈរជើងយ៉ាងរឹងមាំ និងមានប្រៀបឈ្នះគ្រប់គោលដៅសមរភូមិ។

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៥

**Press Release**

**On the Impacts on Civilian Areas and the Protection of Displaced Civilians Resulting from the War of Territorial Aggression by the Bangkok Government and the Thai Military From 7:00 AM until 1:00 PM on 18 December 2025**

From 7 December until 1:00 PM on 18 December 2025, the acts of aggression carried out by the Bangkok Government and the Thai Military against Cambodia, involving indiscriminate attacks, particularly the shelling and aerial bombardment of civilian areas, have resulted in the deaths of 18 Cambodian civilians and injuries to 79 others. These attacks have also caused the displacement of more than 140,000 families, equivalent to over 480,000 people, including more than 240,000 women and over 130,000 children. To date, five provinces that do not share a border with Thailand have received displaced persons.

**From 7:00 AM until 1:00 PM on 18 December 2025, the impacts are as follows:**

1. **Deaths and Injuries**: There are no additional civilian casualties or injuries.
2. **Displacement of Civilians: Preah Vihear Province** has 10,826 displaced families, equivalent to 34,521 people; **Oddar Meanchey Province** has 11,426 families, equivalent to 38,191 people; **Banteay Meanchey Province** has 54,502 families, equivalent to 182,820 people; **Battambang Province** has 12,933 families, equivalent to 46,441 people; **Pursat Province** has 900 families, equivalent to 3,221 people; **Koh Kong Province** has 2,328 families, equivalent to 8,413 people; **Siem Reap Province** has 41,481 families, equivalent to 131,551 people; **Kampot Province** has 3,120 families, equivalent to 9,737 people; **Kampong Speu Province** has 826 families, equivalent to 2,967 people; **Kandal Province** has 1,791 families, equivalent to 6,057 people; and **Kampong Cham Province** has 4,562 families, equivalent to 14,137 people. In total, since the beginning of the conflict, the number of displaced persons has increased to **144,695 families**, equivalent to **478,056 people**, including more than 240,000 women and over 130,000 children.
3. **Destruction of Civilian Infrastructure:** One building, one warehouse roof, and several vehicles were damaged as a result of the Thai military's use of F-16 fighter jets, which dropped three bombs into the area of Phsar Kandal Village, Phsar Kandal Commune, Poipet City. Since 7 December, the total damage has included 67 civilian houses, one school, one healthcare center, one ancient temple, four pagodas, one Buddhist almshouse, one monks' residence, one customs and excise office building, four casino buildings, three hotels, four additional buildings, one community agricultural center, one stone bridge, one steel bridge, one bridgehead, one gas station, five vehicles, one warehouse roof, one cassava storage warehouse, and one ancient bridge. In addition, essential public services, including administrative services, healthcare, and education across cities, districts, and communes, have been almost entirely suspended due to the Thai side's intensified attacks against civilian areas, employing all types and forms of weapons through Royal Thai Army, Royal Thai Navy, and Royal Thai Air Force.

**The Ministry of Interior of the Royal Government of Cambodia** takes great pride in witnessing the powerful and increasingly dynamic momentum of national unity, as Cambodian citizens everywhere around the world have come together in a shared national spirit, standing shoulder to shoulder in support of and with firm confidence in the national defense strategy of **Samdech Akka Moha Sena Padei Techo Hun Sen** and **Samdech Moha Borvor Thipadei Hun Manet**. This great force of national solidarity has provided tremendous moral strength to the Royal Cambodian Armed Forces and the Border Protection Police of the Ministry of Interior, who are jointly standing guard to defend the territorial integrity and national sovereignty with discipline, bravery, and determination, standing firmly and successfully achieving every objective on the battlefield.

Phnom Penh, December 18, 2025